# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យអគ្គនាយកក្រសួងអប់រំ

**440 NORTH BROAD STREET, SUITE 301**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយកក្រសួងអប់រំ*


ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧

ជូនចំពោះ មាតាបិតា និង អាណាព្យាបាល៖

កុមារដែលអានសៀវភៅនៅរដូវក្ដៅ អាចរក្សាចំណេះដឹងរបស់ពួកគេឲ្យបានល្អ ហើយអាចត្រៀមខ្លួនបានល្អប្រសើរសម្រាប់ពេលចូលរៀនវិញនៅក្នុងខែកញ្ញា។ ជាថ្មីម្ដងទៀត សូមជ្រាបថា ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ារីករាយនឹងផ្ដល់សៀវភៅ១០ក្បាល ដល់សិស្សថ្នាក់មុនមត្តេយ្យ ដល់ថ្នាក់ទី២ ទាំងអស់ ព្រមទាំងលំហាត់អក្សរសាស្ត្រ ដើម្បីឲ្យសិស្សហាត់ធ្វើនៅរដូវក្ដៅ។ សៀវភៅទាំងនេះ លោកអ្នកអាចរក្សាទុកជារបស់ក្រុមគ្រួសារលោកអ្នក។

ការជំរុញកូនរបស់លោកអ្នកឲ្យក្លាយទៅជាអ្នកអានជាប្រចាំ គឺអាចមានឥទ្ធិពលយ៉ាងខ្លាំងក្លាដល់ជោគជ័យរបស់កូនលោកអ្នកនៅសាលា។ ខ្ញុំសង្ឃឹមថាលោកអ្នកបានកត់សម្គាល់នូវការរីកចម្រើនកម្រិតនៃការអានរបស់កូនលោកអ្នក ដូចបានបង្ហាញនៅក្នុងរបាយការណ៍ពិន្ទុប្រចាំត្រីមាស ដែលសាលាបានផ្ញើទៅផ្ទះក្នុងឆ្នាំនេះ។ ដើម្បីជ្រាបពីការពន្យល់លម្អិតអំពី កម្រិតនៃការអាន នៅក្នុងរបាយការណ៍ពិន្ទុ ព្រមទាំងចំណេះដឹងនៃការអានដែលក្មេងត្រូវចេះ សម្រាប់ថ្នាក់នីមួយៗ សូមមើលឯកសារតាមអ៊ីនធឺណិត៖
https://webapps1.philasd.org/downloads/tdm/Understanding_Your_Childs_Reading_Levels_K-3_Khmer.pdf.

ខ្ញុំសង្ឃឹមថាសៀវភៅទាំងនេះនឹងផ្ដល់ឱកាសដល់លោកអ្នកក្នុងការចំណាយពេលដ៏មានអត្ថប្រយោជន៍ ដើម្បីអានជាមួយកូនរបស់លោកអ្នក។ សូមអរគុណចំពោះការជំរុញកូនរបស់លោកអ្នកឲ្យក្លាយទៅជា អ្នកអាន និង អ្នកសិក្សា ជាប្រចាំនៅក្នុងជីវិត។ សូមជូនពរឲ្យមានសំណាងល្អ ពោរពេញទៅដោយការចំណាយពេលវេលាជាច្រើនជាមួយក្រុមគ្រួសារ និង ការសប្បាយរីករាយ នារដូវក្ដៅនេះ!

ដោយសេចក្ដីស្មោះត្រង់

William R. Hite, Jr., Ed.D.

WRH/dpw